# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ការអញ្ជើញឲ្យដាក់សំណើដេញថ្លៃ

**ការអញ្ជើញលេខ:** CDRR/BMC-CANAL-0102

**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ**

**គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន**

**សមាសភាព** C

មូលនិធិលេខ: 9178-CAM

មានបំណងជ្រើសរើសអ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចខាងក្រោម: ឈ្មោះកិច្ចសន្យា: ស្តារប្រឡាយដី ប្រវែង ៤១៥០ម និងសង់លូប្រអប់ទោលមានទ្វារទឹកបន្ទះក្តារ ទំហំ ១២,៥៧មx២,៤ម x២,៥៥ម ចំនួន០១កន្លែង ស្ថិតនៅភូមិជួរខ្វាស់ ភូមិបឹងត្រស់ ភូមិដងត្រាង ឃុំចំណោម ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការចំណាយលើគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅសហគមន៍មូលដ្ឋាន ហើយមានបំណងប្រើប្រាស់មួយផ្នែកនៃជំនួយឥតសំណងនេះសម្រាប់ចំណាយលើកិច្ចសន្យា ស្តារប្រឡាយដី ប្រវែង ៤១៥០ម និងសង់លូប្រអប់ទោលមានទ្វារទឹកបន្ទះក្តារ ទំហំ១២,៥៧មx២,៤ម x២,៥៥ម ចំនួន០១កន្លែង (CDRR/BMC-CANAL-0102)។

២. តម្លៃប៉ាន់ស្មានសម្រាប់កិច្ចសន្យានេះគឺ ៣០,៦៨២.៨៨ ដុល្លារសហរដ្ឋអាមេរិក (បីម៉ឺនប្រាំមួយរយប៉ែតសិបពីរដុល្លារ និងប៉ែតសិបប្រាំបីសេន)។

៣. កាលវិភាគសាងសង់មានរយៈពេល០២ខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើម

៤. អ្នកទទួលការមានសិទ្ធិ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានចំណាប់អារម្មណ៍ ត្រូវបានអញ្ជើញឱ្យមកទទួលយកឯកសារដេញថ្លៃចំនួនមួយច្បាប់ដោយឥតគិតថ្លៃនៅអាសយដ្ឋានខាងក្រោម។

៥. ដើម្បីក្លាយជាអ្នកដែលមានសិទ្ធិ អ្នកទទួលការត្រូវ ៖

ក.អ្នកទទួលការត្រូវមានបទពិសោធន៍លើការសាងសង់សំណង់ដី និងសំណង់បេតុង( ស្ពាន លូ ទ្វារទឹក ផ្លូវ ទំនប់ ។ល។

ខ. បានចុះបញ្ជីការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ. មិនឋិតនៅក្រោមការហាមឃាត់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឬធនាគារអភិវឌ្ឍន៍អាស៊ី។

៦. ដើម្បីចាត់ទុកជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកទទួលការត្រូវ ៖

ក. ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ ធ្លាប់បានបញ្ចប់កិច្ចសន្យាយ៉ាងតិចចំនួន២ នៃប្រភេទការងារប្រហាក់ប្រហែលគ្នាដែលកិច្ចសន្យានិមួយៗមានតម្លៃយ៉ាងតិច ៧៥%នៃតម្លៃដាក់ដេញថ្លៃ ។



Scanned by CamScanner

ខ. រយៈពេល២ឆ្នាំចុងក្រោយអ្នកម៉ៅការត្រូវមានផលរបរសរុបប្រចាំឆ្នាំចំនួនយ៉ាងតិច១.៥ដង នៃតម្លៃដាក់ដេញថ្លៃ។

គ. អ្នកគ្រប់គ្រងសំណង់ដែលស្នើមក ត្រូវមានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ ក្នុងការត្រួតពិនិត្យការងារដែលមានលក្ខណៈប្រហាក់ប្រហែល និងធ្លាប់មានតួនាទីជាអ្នកគ្រប់គ្រងការងារសំណង់ ក្នុងរយៈពេលមិនតិចជាង១ឆ្នាំ។ឯកសារដែលជាភស្តុតាងបង្ហាញអំពីលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃត្រូវដាក់ភ្ជាប់មកជាមួយសំណើដេញថ្លៃ។

៧. សំណើដេញថ្លៃទាំងអស់ត្រូវដាក់មកអាស័យដ្ឋានខាងក្រោមនៅត្រឹមឬមុនម៉ោង៩.០០នាទីព្រឹកថ្ងៃទី២៥ខែតុលាឆ្នាំ ២០១៧ ។ សំណើដេញថ្លៃណាដែលដាក់មកយឺត នឹងត្រូវបានបដិសេធចោល។ សំណើដេញថ្លៃដែលបានទទួលនឹងត្រូវបានបើកជាសាធាណៈភ្លាមៗ ក្រោយកាលបរិច្ឆេទផុតកំណត់នៅអាស័យដ្ឋានដដែល ដោយមានវត្តមានតំណាងអ្នកដេញថ្លៃទាំងអស់ ហើយអ្នកទទួលផលគម្រោងពីសហគមន៍មូលដ្ឋានដែលពាក់ពន្ធ័ ដែលមានបំណងចង់ចូលរួម ត្រូវបានអនុញ្ញាតិអោយចូលរួមដោយផ្ទាល់ ។

អាសយដ្ឋានសម្រាប់ដាក់សំណើដេញថ្លៃ និងបើកសំណើដេញថ្លៃ គឺៈ

អាសយដ្ឋានៈ សាលាស្រុកមង្គលបូរីស្ថិតនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

បន្ទប់ៈ (សាលប្រជុំ របស់សាលាស្រុកមង្គលបូរី)

៨. ម្ចាស់គម្រោងនឹងផ្តល់កិច្ចសន្យាដល់អ្នកដេញថ្លៃណា ដែលត្រូវបានពិនិត្យឃើញថា សំណើដេញថ្លៃមានតម្លៃទាបជាងគេបំផុតនឹងឆ្លើយតបទាំងស្រុងទៅតាមលក្ខខណ្ឌតម្រូវនានានៃឯកសារដេញថ្លៃ ហើយអ្នកដេញថ្លៃនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យាដោយការពេញចិត្ត។

៩. សំណើដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវលិខិតប្រកាសស្តីពីការធានាសំណើដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យា (bid and performance securing declaration) ដូចបានរៀបរាប់ក្នុងសេចក្តីណែនាំ សម្រាប់អ្នកដេញថ្លៃ (Instructions to Bidders) ។ ចំពោះសំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកនូវលិខិតប្រកាសស្តីពីការធានាសំណើរដេញថ្លៃ និងការអនុវត្តន៍កិច្ចសន្យានេះ នឹងត្រូវបដិសេធន៏ចោលដោយចាត់ទុកថាមិនបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ។

១០. អាសយដ្ឋានដើម្បីសាកសួរព័ត៌មាន និងទទួលយកឯកសារដេញថ្លៃគឺៈ

ឈ្មោះមិន និមល មន្ត្រីហិរញ្ញវត្ថុស្រុក

អាសយដ្ឋានៈសាលាស្រុមង្គលបូរី

អ៊ីម៉ែលៈminniomol550@gmail.com

លេខទូរសព្ទ័ៈ០៧៧ ២៣៤ ៨៤៨

ម៉ោងការងារ ព្រឹកៈ ៨.៣០ - ១១.៣០ , ល្ងាចៈ ២.៣០ - ៤.៣០

១១. ក្នុងករណីដែលមានការលំបាកក្នុងការទទួលឯកសារដេញថ្លៃ ភាគីទាំងឡាយដែលមានចំណាប់អារម្មណ៍ អាចទាក់ទងជាលាយលក្ខណ៍អក្សរមក

ឯកឧត្តម នី គឹមសាន, ប្រធានគម្រោង, លេខាធិការដ្ឋាន គ.ជ.អ.ប



Scanned by CamScanner

អាសយដ្ឋានៈ មហាវិថីនរោត្តម ចំការមន ភ្នំពេញ
អ៊ីម៉ែលៈ kimsanny1973@gmail.com
និងផ្ញើឯកសារដែល ទំនាក់ទំនងនោះមួយច្បាប់ផងដែរទៅ
លោក **យី សុខធារិទ្ធ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ផ្លូវ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, ភ្នំពេញ, កម្ពុជា
អ៊ីម៉ែលៈ sokthearith_yi@mef.gov.kh

១២. រាជរដ្ឋាភិបាលកម្ពុជា និង ធានាគារអភិវឌ្ឍន៍អាស៊ី នឹងប្រកាសរៀងៗខ្លួនអំពីការដកសិទ្ធិទាំងស្រុងពីក្រុមហ៊ុនដោយមិនកំណត់ពេល ឬក្នុងរយៈពេលកំណត់ណាមួយ ពីការទទួលបានកិច្ចសន្យាដែលប្រើប្រាស់មូលនិធិរាជរដ្ឋាភិបាលកម្ពុជា និងធានាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាមួយដែលពិនិត្យឃើញថាក្រុមហ៊ុននោះជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ឬអំពើកេងបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំ ក្នុងការប្រកួតប្រជែងដើម្បីទទួលបានកិច្ចសន្យា ឬក្នុងពេល អនុវត្តកិច្ចសន្យា។

១៣. ភាគីពាក់ពន្ធ័អាចប្តឹងតវ៉ានៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការលទ្ធកម្ម។ នីតិវិធីនៃការប្តឹងតវ៉ាបានរៀបរាប់ក្នុង ប្រការ ២១ នៃ សេចក្តីណែនាំសម្រាប់អ្នកដេញថ្លៃ ។

យើងខ្ញុំរង់ចាំទទួលសំណើដេញថ្លៃពេញលេញ និង ឆ្លើយតបតាមលក្ខខណ្ឌតម្រូវ មុនកាលបរិច្ឆេទផុតកំណត់ដែលបានបញ្ជាក់ខាងលើ និង តាមលក្ខខណ្ឌដែលបានរៀបរាប់ក្នុងឯកសារដេញថ្លៃដោយសេចក្តីរាប់អាន។

សាលាស្រុកមង្គលបូរី ថ្ងៃទី..០៥...ខែ ..តុលា.. ឆ្នាំ ២០១៧
ហត្ថលេខា និងត្រា

រ័ត្ន ជាស៊ីណាច់

Scanned by CamScanner